**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ឧត្តរមានជ័យ**
**លេខ......V.........អយកខ.សជណ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការផ្អាកដំណើរការបង្រៀន និងរៀន ជាបណ្តោះអាសន្ន ក្នុងខេត្តឧត្តរមានជ័យ

យោង៖ - សភាពការណ៍តាមបណ្តោយព្រំដែនកម្ពុជា ថៃ

- អនុសាសន៍ណែនាំ របស់ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ
- អនុសាសន៍ណែនាំ ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

មន្ទីរអប់រំ យុវជន និងកីឡាខេត្តឧត្តរមានជ័យ សូមគោរពជម្រាបជូន គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា លោកគ្រូ អ្នកគ្រូ បុគ្គលិកអប់រំ អ្នកអាណាព្យាបាល និងសិស្សានុសិស្សទាំងអស់ ជ្រាបថា៖ ក្រោយពីមានការឈ្លានពានពីសំណាក់យោធាថៃមកលើព្រំដែន នៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ វេលាម៉ោង ០៥:០៤ នាទីព្រឹក ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៥ នេះ មន្ទីរអប់រំ យុវជន និងកីឡាខេត្តឧត្តរមានជ័យ សម្រេចអនុញ្ញាតឱ្យគ្រឹះស្ថានសិក្សាទាំងអស់ក្នុងខេត្តផ្អាកដំណើរការបង្រៀន និងរៀនជាបណ្តោះអាសន្ន រហូតដល់មានការជូនដំណឹងជាថ្មី ដើម្បីធានាសុខសុវត្ថិភាពដល់ លោកគ្រូ អ្នកគ្រូ បុគ្គលិកអប់រំ និងសិស្សានុសិស្សទាំងអស់ បញ្ចៀសបាននូវគ្រោះថ្នាក់ដែលបណ្តាលមកពីការបាញ់ប្លោងកាំភ្លើងធំរបស់ភាគីថៃមកក្នុងទឹកដី នៃព្រះរាជាណាចក្រកម្ពុជា។

សេចក្តីដូចបានគោរពជម្រាបជូនដំណឹងខាងលើ សូម គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា លោកគ្រូ អ្នកគ្រូ បុគ្គលិកអប់រំ អ្នកអាណាព្យាបាល និងសិស្សានុសិស្សទាំងអស់ ជ្រាបជាព័ត៌មាន និងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃចន្ទ ៣រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ខេត្តឧត្តរមានជ័យ ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥

**ចម្លងជូន៖**
- ក្រសួងអប់រំ យុវជន និងកីឡា
- រដ្ឋបាលខេត្តឧត្តរមានជ័យ
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- រដ្ឋបាលក្រុង ស្រុក"ដើម្បីអនុវត្ត"
- ឯកសារ
- កាលប្បវត្ត កាវិ.របប

CS Scanned with CamScanner